ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កោះធំ

ភូមិ : កោះធំ

ឃុំ : ព្រៃគ្រី

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កោះធំ

ភូមិ : កោះធំ

ឃុំ : ព្រៃគ្រី

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

## ផែនការគ្រប់គ្រង
## តំបន់នេសាទសហគមន៍

### ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **កោះធំ** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៣** ខែ **កក្កដា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **កោះធំ** មានទីតាំងស្ថិតនៅក្នុងភូមិ **កោះធំ** ឃុំ **ព្រៃគ្រី** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២៣០** នាក់ ស្រីចំនួន **៨១** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **គ្មាន**។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **១១០** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- ចុះបង្ក្រាបបទល្មើស អួនស៊ៃមុង
- ចុះណែនាំអ្នកប្រើរបាំងលប
- ចុះបង្ក្រាបអ្នកដងកូនត្រីឆ្តោរ

### ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

**ក-ប្រជាពលរដ្ឋ:**

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **១៤២៦** នាក់ ប្រុស **៨៣០** នាក់ ស្រី **៥៩៦** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **១៤២៦** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាម **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៣៩ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៦ នាក់ ស្រី ៥នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៣ នាក់ ស្រី ១០ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១ នាក់ ស្រី គ្មាន
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៦នាក់ ស្រី ៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ីស្លាម ប្រមាណ **គ្មាន %** សាសនាកាតូលិក **គ្មាន %**
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៨៩ នាក់ ស្រី ៦៥ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១៣២ នាក់ ស្រី ៦២ នាក់ កំរិតមធ្យមសិក្សាចំនួន ២០ នាក់ ស្រី ៥ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន គ្មាន

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ៩០ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ១១០ គ្រួសារ ទំហំ ១៧០ហិកតា
- ធ្វើវារីវប្បកម្មចំនួន ១១ គ្រួសារ ទំហំ ហិកតា ឬចំនួន ៩ បែ, ស្រះ ៥
- ដាំបន្លែចំនួន ៧ គ្រួសារ ទំហំ ២ ហិកតា
- ជាងផ្ទះចំនួន ៥ គ្រួសារ
- ធ្វើចំការចំនួន ១១០ គ្រួសារ ទំហំ ១៥ ហិកតា
- ធ្វើសិប្បកម្មចំនួន ៥ គ្រួសារ ( ធ្វើទូក )
- លក់ដូរ ចំនួន ២១ គ្រួសារ
- ឈ្នួញទិញត្រី ៥ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **កោះធំ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៥** និងជាដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **កោះធំ** មានទំហំ **៦៥៤ ហិកតា** និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **មាត់បឹងកំពិស**
- ខាងត្បូងទល់នឹង **ទំនប់តាហៃ**
- ខាងកើតទល់នឹង **ចុងទំនប់តាវ៉ាន់**
- ខាងលិចទល់នឹង **ពាក់កណ្ដាលមេទឹកតាម៉ៅ ខាងកើតចុងត្បូងជាប់មាត់បឹងចកលុះ**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **កោះធំ** មានបឹងចំនួន **៨** ព្រែក ចំនួន **៣** ប្រឡាយចំនួន **២** អូរចំនួន **១** ស្រះ ចំនួន **៥** មេទឹកចំនួន **៣** និង បែរ **៩** ។

- បឹងឈ្មោះ **កំពិស** ទំហំ ១ ហិកតា នេសាទពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **ប្រចរតូច** ទំហំ ០,៤ ហិកតា នេសាទពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **ប្រចរធំ** ទំហំ ០,៦ ហិកតា នេសាទពីខែ មិនា ដល់ខែ មេសា

- បឹងឈ្មោះ **ប្រយ៉ាប** ទំហំ ១ ហិកតា នៅរដូវប្រាំងពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **សន្ធរ** ទំហំ ០,៥ ហិកតា នៅរដូវប្រាំងពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **សន្ទុះ** ទំហំ ១០,៥ ហិកតា នៅរដូវប្រាំងពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **អាចិល** ទំហំ ៣ ហិកតា នៅរដូវប្រាំងពីខែ មិនា ដល់ខែ មេសា
- បឹងឈ្មោះ **ខ្វែងគ្រូច** ទំហំ ១៥ ហិកតា នៅរដូវប្រាំងពីខែ កក្កដា ដល់ខែ មេសា
- បឹងឈ្មោះ **ទទឹងថ្ងៃ** ទំហំ ១៥ ហិកតា នៅរដូវប្រាំងពីខែ កក្កដា ដល់ខែ មេសា
- ព្រែកឈ្មោះ **ព្រះច័ន្ទ** ទំហំ ៤,៥ ហិកតា នៅរដូវប្រាំងពីខែ វិច្ឆិកា ដល់ខែ មិនា
- ព្រែកឈ្មោះ **កំពង់ស្ពាន** ទំហំ ២,៦ ហិកតា នៅរដូវប្រាំងពីខែ វិច្ឆិកា ដល់ខែ មិនា
- ព្រែកឈ្មោះ **ខ្វែងគ្រូច** ទំហំ ០,២៥ ហិកតា នៅរដូវប្រាំងពីខែ វិច្ឆិកា ដល់ខែ មិនា
- ប្រឡាយឈ្មោះ **ទំនាបយាយឡាយ** ទំហំ ១០០ម x ២០ម
- ប្រឡាយឈ្មោះ **អូរតាស** ទំហំ ១០០ម x ១៥ម
- មេទឹកឈ្មោះ **តាម៉ៅ** ទំហំ ២០០០ម x ៥០០ម
- មេទឹកឈ្មោះ **តាកែវ** ទំហំ ៣០០ម x ២០០ម
- មេទឹកឈ្មោះ **សន្ធរ** ទំហំ ៦០០ម x ១៥០ម
- អូរឈ្មោះ **តាបុក** ទំហំ ២០០ម x ៥ម
- ស្រះចំនួន ៥ ទំហំ ២៦៥០ ម៉ែត្រការ៉េ
- បែរចំនួន ៩ ទំហំ ៤៥ ម៉ែត្រការ៉េ

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងឈ្មោះ **បឹងខ្វែងគ្រូច** ទំហំ ១៥ ហិកតា ( បណ្តោយ ១០០០ ម ទទឹង ១៥០ម )

## ឃ. ធនធានជលផល

**ប្រភេទត្រី :** ច្រឡឹង រ៉ស់ ក្លាំងហាយ ឆ្តោរ ឆ្អិន ពោរ ប្រា ច្រកែង ក្រុសមេម៉ាយ ឆ្ពោក ព្រួល ស្រកាក្ដាម ក្រាញ់ កន្ទ្រប់ កន្ធរ កំភ្លាញ អណ្តែង ខ្ទីង ឆ្លាំង កញ្ចុះ អណ្តាតឆ្កែ ប្រម៉ា ខ្លា ឈ្សើត ជន្លាសក្លុក ច្រវាមូល ផ្ទោង ទីឡាព្យា ឆ្លូញ ស្លាត កេស ក្អី ក្អុក ឆ្ពោកទីទុយ គល់រាំង កាហោ ត្រសក់ ច្រចៀកឡា ខ្លា កៀតស្រង ប្រាខ្មៅ កន្ត្រងព្រែង កញ្ច្រាញ់ច្រាស់ កន្ទ្រាច រំចេក រៀល លិញ ច្រឡឹង ក្រុសខ្នងវែង កញ្ចុះថ្ម ក្របី ឆ្មា កំភ្លៀវ

- **ប្រភេទវារីសត្វ :** កុក ក្រសា ទុង ក្អែកទឹក ទោម មាន់ទឹក ក្របិត អណ្តើក ពស់ កន្ធាយ លលក ទាប ត្រកួត

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងភាវរុក្ខជាតិ** : រាំង អញ្ចាញ ត្រស់ ផ្ទើមអណ្តើក ខ្ទុម បបួយ ទានព្រៃ ត្រែង កប្បាសព្រៃ ឡាបគុប ភ្នំភ្លើង ញរ បន្ទាយូន។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២០០ នាក់ ស្រី ៥៥ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍ចំនួន ៣០ នាក់ ស្រី ១២ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ១២០ នាក់ ស្រី ៧០ នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ដៃ | ដៃ= ៩០ម | ៩០ម x ៨៥នាក់ x៤ដៃ= ៣០៦០០ម | កក្កដា-មិនា |
| អួន | វង់ | វង់=៨០ម | ៤វង់ x ៨០ម= ៣២០ម | មេសា-មិថុនា |
| សន្ទូចរនង | ផ្លែ | ១០០០ផ្លែ | ១០០០ផ្លែ x ៨០នាក់ = ៨០០០០ផ្លែ | កក្កដា-មិនា |
| លប | លប | ៣០លប | ៥៥នាក់ x ៧ = ៣៨៥លប | កក្កដា-កុម្ភៈ |
| សំណាញ់ | វង់ | ៣០វង់ | ១៥វង់ | ធ្នូ- មិថុនា |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| កាណូតម៉ាស៊ីន(Masda ) | ១២០ | ១ តោន-៧ តោន | ៦-១៥ សេះ |
| កាណូតម៉ាស៊ីន | ១១០ | 0.៧ តោន | ៦ សេះ |
| ទូកចែវ | ២២៧ | | |
| ទូកត្នោត | ៤ | | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** |
|---|---|---|---|
| មង | ដៃ | ដៃ= ៩០ម | ៩០ម x ២០នាក់ x៤ដៃ= ៧២០០ម |
| អួន | វង់ | វង់=៨០ម | ១វង់ x ៨០ម= ៨០ម |

| | | | |
|---|---|---|---|
| អួន | វង់ | វង់=៨០ម | ១វង់ x ៨០ម= ៨០ម |
| សន្ទូចរនង | ផ្លែ | ១០០០ផ្លែ | ១០០០ផ្លែ x ២៥នាក់ = ២៥០០០ផ្លែ |
| លប | គ្រឿង | | ៥នាក់ x ៣០ = ១៥០លប |
| សំណាញ់ | វង់ | | ៤ វង់ |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ធំជាង ៦ សេះ | ០ | ០ | |
| តូចជាង ៦ សេះ | ៤ | ០.៧ តោន | តូចជាង ៦សេះ |
| ទូកចែវ | ២០ | ០.៥ តេន | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** |
|---|---|---|---|
| មងប្រយុង | វង់ | ៥០ | |
| មងពាក់ | វង់ | ៥០ | |
| សន្ទូចបង្កៃ | ផ្លែ | ១៥០ផ្លែ x ៥០នាក់ | |
| អង្រុត | គ្រឿង | ១២០ | |
| លប | គ្រឿង | ១០គ្រួសារ x ៤ | ៤០ គ្រឿង |
| សំណាញ់ | វង់ | ១៥ | ១៥ វង់ |
| អួន | វង់ | ២០ x ៣០ម | ៦០០ម |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| កង់ | ២០ | | |
| ម៉ូតូ | ១៥ | | |

**គ.   ប៉ាន់ប្រមាណ   ផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ២១៥០ គ.ក្រ | ៤០០ គ.ក្រ | ១៥៥០ គ.ក្រ |
| ក្តាម ខ្យង | ១៥០ គ.ក្រ | ៥០ គ.ក្រ | ២០០ គ.ក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនះវិស័យ

សហគមន៍នេសាទ **កោះធំ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងព្រះច័ន្ទ | វិច្ឆកា-មិនា | មង | ៨០ ម | ១៦០០ ម | |

#### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងខ្លែងគ្រួច | ១៥ហិកតា | ៣ ហិកតា | ស្តារ | មេសា ២០០៨ | មិថុនា ២០០៨ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងខ្លែងគ្រួច | ៣ហិកតា | ត្រីមេពូជ | រៀបចំ | មិថុនា ២០០៨ | មិថុនា ២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

-ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក ឡើងវិញ មាត់បឹងខ្លែងគ្រួច | ១.៥ហិកតា | រាំង ត្រស់ ចង្កេង | ដាំឡើងវិញ | មិថុនា ២០០៨ | មិថុនា ២០០៩ | |
| ២-ថែរក្សា និងរំលោះព្រៃលិចទឹកមាត់បឹងខ្លែងគ្រួច | ៣ហិកតា | រាំង ត្រស់ ចង្កេង | ថែរក្សា | មិថុនា ២០០៨ | មិថុនា ២០១០ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| បែរ | ១០ | ព្រលូង | ១៥០០០កូន | មិថុនា ២០០៨ | មិថុនា ២០០៩ |
| ស្រះ | ៥ | ប្រា អណ្តែង ឆ្តិន | ៥០០០កូន | ២០០៨ | ២០១០ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូល | ២០០៩ | ២០១០ | | |
| ភាគទានប្រចាំឆ្នាំ | | មិនទាន់ចាប់ផ្តើម | មិនទាន់ចាប់ផ្តើម | | |
| ជំនួយសប្បុរសជន និងអង្គការនានា | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| CCD ជយយសំភារៈ( ម៉ាស៊ីនថត អាវភ្លៀងអង្រឹង | | | ២០០៦ | | |

## គ-៧ ផែនការបង្កើនមុខរបរគ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ២០០៨ | ២០១០ |
| ដាំបន្លែ (ននោង, សណ្តែកគួ ស្ពៃខៀវ, ស្ពៃចង្កឹះ...) | ២០ គ្រួសារ | ២០០៨ | ២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២រង (១០គ្រួសារ) | ២០០៨ | ២០១០ |

## គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៣ បង្គោល (PIU) | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៨ | មិនា ២០០៨ | ត្រូវការជំនួយ និងការសហការពីស្ថាប័នជំនាញ និងអង្គការនានា |

## គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | PIU និង FAO |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | PIU និង FAO |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និងគណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | PIU និង FAO |

| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | PIU និង FAO |
|---|---|---|---|

## គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និង ការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៨ | PIU និង FAO |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៨ | PIU និង FAO |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | PIU និង FAO |
| | ការទំនាក់ទំនង និង សរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៨ | PIU និង FAO |
| | រៀបចំបណ្ដាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៨ | PIU និង FAO |
| | ទស្សនៈកិច្ចសិក្សារផ្លាស់ប្ដូរ បទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | PIU និង FAO |
| បណ្ដុះបណ្ដាល បច្ចេកទេស | បណ្ដុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | តុលា ២០០៨ | PIU និង FAO |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៨ | PIU និង FAO |
| | បណ្ដុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៨ | PIU និង FAO |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៏ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្ដល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្ដារព្រៃ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កោះធំ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់ បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ១៥០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៨ | ២០១០ | |
| ២. ការកែលំអដែននេសាទ | - ស្តារបឹងខ្លែងក្រូច ទំហំ ៣ ហ.ត | - សមាជិកសហគមន៍នឹង ទទួលផលប្រយោជន៍ ពីការប្រើប្រាស់ទឹក និងធនធានធម្មជាតិជាពិសេសត្រីពីក្នុងបឹង | - ចំណាយសរុប ៣០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មេសា ២០០៨ | មិថុនា ២០០៨ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | - ពិភាក្សាជាមួយសមាជិកសហគមន៍ ដើម្បីចុះកំនត់តំបន់អភិរក្សជាក់ស្តែង<br>- សុំការគាំទ្រពីអាជ្ញាធរភូមិ-ឃុំ<br>- រៀបចំសំណើសុំថវិកា និងស្វែង | - បឹងខ្លែងក្រូច និង ត្រូវកំនត់ជាកន្លែងអភិរក្សត្រី មេពូជ<br>- ព្រៃលិចទឹកជុំវិញបឹងខ្លែងក្រូចចំនួន ៣ ហ.ត នឹងត្រូវដាក់ជាព្រៃអភិរក្ស | - ចំណាយសរុប ២៥០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មិថុនា ២០០៨ | មិថុនា ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រកការគាំទ្រ<br>- ចុះកំណត់ព្រំប្រទល់, បោះ, បង្គោល, ដាក់ស្លាកសញ្ញា,ទំលាក់លូ និងគល់ឈើចុះយាមល្បាតតាមផែនការកំណត់ | - ធនធានធម្មជាតិ ( ត្រី, ព្រៃលិចទឹក និងសត្វគ្រប់ប្រភេទ) នឹងកើនឡើង | | | | | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - ផ្សព្វផ្សាយពីសារប្រយោជន៍ព្រៃលិចទឹកជាសាធារណៈ ។<br>- កំណត់កន្លែងត្រូវដាំព្រៃលិចទឹក និងយុទ្ធនាការដាំ<br>- ដាក់ស្លាកសញ្ញាហាមកាប់បំផ្លាញព្រៃលិចទឹក និងត្រួតពិនិត្យឃ្លាំមើល | - ត្រូវបានកំនត់ជា តំបន់ដែលត្រូវដាំព្រៃឡើងវិញ<br>- ចំនួន ១,៥ ហ.តត្រូវបានបណ្តុះ និងដាំ | - ចំណាយសរុប ១០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មិថុនា ២០០៨ | មិថុនា ២០១០ | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - ផ្សព្វផ្សាយពីការចិញ្ចឹមត្រីក្នុងស្រះ និង បែរ | - សហគមន៍ចំនួន១០គ្រួសារនឹងសាកល្បងអនុវត្តការចិញ្ចឹមត្រីក្នុងស្រះ បែរ ជាមួយនិងកូនត្រីព្រលូង, ប្រា,អណ្តែង, ឆ្តិន<br>- ពូជ ចំនួន ១៥០០០កូន | - ចំណាយសរុប ១៥០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៨ | មករា ២០០៩ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | - សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានានឹងជួយគាំទ្រតាមរយៈការផ្តល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | ២០០៨ | ២០១០ |
| ៧- ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាពជំរើសមុខរបរចិញ្ចឹមជីវិត<br>- ស្វែងរកអង្គការ ស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព<br>- សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៨ | ២០១០ |
| ៨- ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ | - សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | - បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី<br>- ស.នមានព្រំប្រទល់ច្បាស់លាស់កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | កុម្ភៈ ២០០៨ | មិនា ២០០៨ |
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់ | - ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា | មករា ២០០៨ | ធ្នូ ២០១០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ និងស.ន | | | - ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | | | |
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ស.គចេះជំនាញផ្សេងៗទាក់ទិន និងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៨ | ធ្នូ ២០០៨ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |

ធ្លកកុំ ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ឈួន

លេខ : 02 ស.ក

បានឃើញ និងបញ្ជូនមក

**បានឃើញ**

**មេឃុំ** ...ធ្លកកុំ...

ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

ហ៊ាន់-យឿន

លេខ : 381 ក.ន

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល** ...

ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

ស៊. ...

លេខ : .................

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០8

**នាយអធិការដ្ឋានរដ្ឋបាលជលផល** ...

ហ៊ុន-ហ៊ី

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល ...

ថ្ងៃទី 21 ខែ 10 ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល** ...

...